នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Mar-2011, 15:41
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត សាធារណៈ/Public

រឺ អង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹង “ អង្គហេតុដែលមិនជំទាស់តវ៉ា ”

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក សរ សូវ៉ាន
លោក Jacques VERGÈS
លោក Phillipe GRECIANO

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសង*

## I. សេចក្តីផ្តើម

១. អនុលោមតាម ដីកាបង្គាប់ឲ្យត្រៀមរៀបចំសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១[1] សហព្រះរាជអាជ្ញាសូមផ្តល់យោបល់ជូនអង្គជំនុំជម្រះថា សហព្រះរាជអាជ្ញាគ្មានលទ្ធភាពដើម្បីឈានដល់ការឯកភាពលើបញ្ជីរួមនៃអង្គហេតុដែលមិនជំទាស់តវ៉ាជាមួយមេធាវីការពារក្តីទេ។ ដីកាបង្គាប់តម្រូវឲ្យសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីនិមួយៗដាក់បញ្ជីរួមនៃអង្គហេតុដែលគ្មានការជំទាស់តវ៉ា អនុលោមតាមវិធាន៨០(៣)(ង) នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក មិនឲ្យហួសពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១[2] ។

២. ដើម្បីជួយឲ្យសម្រេចបាននូវការព្រមព្រៀងគ្នា នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានផ្ញើការអញ្ជើញមួយតាមអ៊ីម៉េល ក្នុងទម្រង់ជាអនុស្សរណៈ ដែលនៅក្នុងនេះក៏បានគូសបង្ហាញពីគម្រោងរួមដែលអាចនឹងត្រូវកត់ត្រាទុកចំពោះអង្គហេតុទាំងឡាយដែលពុំមានការជំទាស់តវ៉ា (សូមអាន **ឧបសម្ព័ន្ធ ១**)។ ជំពូក១ និងជំពូក៤ នៃដីកាដំណោះស្រាយត្រូវបានភ្ជាប់ទៅជាមួយនឹងអ៊ីម៉េលនេះ ក្នុងទម្រង់ជា OCR ដើម្បីអាចបញ្ជាក់បង្ហាញជាអេឡិចត្រូនិចចំពោះអង្គហេតុ ឬផ្នែកណាដែលគ្មានការជំទាស់តវ៉ា (សូមអាន **ឧបសម្ព័ន្ធ ២**)[3]។ ក្រុមមេធាវីការពារក្តីនិមួយៗត្រូវបានស្នើឲ្យផ្ញើត្រឡប់មកឲ្យសហព្រះរាជអាជ្ញាវិញ ជាច្បាប់អេឡិចត្រូនិច ចំពោះអង្គហេតុណាមួយដែលគ្មានការជំទាស់តវ៉ា ដើម្បីអាចឲ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបរួមមួយបាន។ សម្រាប់មូលហេតុផ្សេងៗដែលបានផ្តល់ដោយក្រុមមេធាវីការពារក្តីនិមួយៗនៅក្នុងអម្លុងពេលនៃការដាក់ចម្លើយតបនេះ គឺពុំបានទទួលការព្រមព្រៀងគ្នាអំពីអង្គហេតុដែលគ្មានការជំទាស់តវ៉ាទេ។ មូលហេតុដែលបានផ្តល់ជូនមានដូចខាងក្រោម៖

១) មេធាវីការពារក្តី អៀង ធីរិទ្ធ បានឆ្លើយតបតាមអ៊ីម៉េលនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១ ដោយបានថ្លែងថាមិនអាចទទួលបាននូវការណែនាំពីកូនក្តីរបស់ខ្លួនទេនៅពេលនេះ។

---

[1] ឯកសារលេខ E9, “ ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ”, ១៧ មករា ២០១១, ERN 00635754-5759។

[2] ដីកាបង្គាប់ឲ្យត្រៀមរៀបចំសវនាការ, កថាខណ្ឌទី៩។

[3] ឯកសារ D427 “ ដីកាដំណោះស្រាយ ” ចុះថ្ងៃ១៥ កញ្ញា ២០១០, ERN00604508-5246, ទំព័រ១៣-៣២៣ និង៣៩០-៣៩៦។

២) មេធាវីការពារក្ដី ខៀវ សំផន បានឆ្លើយតបតាមរយៈការដាក់ឯកសារទៅតុលាការនៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១១ ដោយបានថ្លែងថា[4]៖

"លោក ខៀវ សំផន ត្រូវបានសន្មតថា គ្មានទោស[5]។ បន្ទុកភស្តុតាងនៃទណ្ឌភាពរបស់ជនជាប់ចោទត្រូវធ្លាក់ទៅលើសហព្រះរាជអាជ្ញា[6]។ ទោះជាលោក ខៀវ សំផន មិនទទួលស្គាល់អំពើណាមួយដែលមានចែងក្នុងដីកាដំណោះស្រាយ ដែលដាក់ពិរុទ្ធទៅលើរូបលោកក៏ដោយ ក៏លោកនៅតែយល់ព្រមរួមចំណែកយ៉ាងសកម្មក្នុងដំណើរការស្វែងរកយុត្តិធម៌ ដោយបកស្រាយនូវគំនិតផ្ទាល់របស់លោកទៅលើអំពើទាំងនោះ នៅក្នុងដំណើរការកាត់សេចក្ដីក្នុងគោលបំណងស្វែងរកការពិតនិងប្រវត្តិសាស្ត្រ ដើម្បីជាប្រយោជន៍ដល់សហគមន៍អន្តរជាតិ និងប្រជាពលរដ្ឋកម្ពុជា" ។

៣) មេធាវីការពារក្ដី អៀង សារី បានឆ្លើយតបតាមលិខិត នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ដោយបានថ្លែងថាពួកខ្លួនបានភ្ជាប់ដីកាដំណោះស្រាយជាទំរង់ PDF ដោយមានដាក់ពណ៌បៃតងលើផ្នែកដែលលោកអៀង សារី មិនជំទាស់ជាមួយនឹងការអធិប្បាយ ដើម្បីបញ្ជាក់អោយកាន់តែច្បាស់ថា តើហេតុអ្វីផ្នែកនៅក្នុងការកំណត់ទោសមិនត្រូវបានយល់ស្របតាមជាកន្លែងដែលតំរូវអោយមានការផ្លាស់ប្ដូរ រឺក៏មានភាពមិនស្របគ្នានៅក្នុងការបកប្រែ។ Annex3 រួមមានលិខិតភ្ជាប់ និងជាផ្នែកអំពីអង្គហេតុជាក់ស្ដែងទាំងឡាយនៃដីកាដំណោះស្រាយដែលបានដាក់ពណ៌ ដោយក្រុមការពារ លោកអៀង សារី។

៤) មេធាវីការពារក្ដី នួន ជា បានឆ្លើយតបតាមរយៈការដាក់ឯកសារនៅតុលាការនៅថ្ងៃនេះ ដោយបានថ្លែងថា ក្រុមមេធាវីការពារក្ដីបានជំរាបមកការិយាល័យសហព្រះរាជអាជ្ញាថា នៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី ក្រុមមេធាវីការពារក្ដីមិនអាចឈានដល់នូវការព្រមព្រៀងមួយជាមួយនឹងការិយាល័យសហព្រះរាជាអាជ្ញាទៅនឹង"អង្គហេតុ"ណា

[4] ឯកសារលេខ E9/17, " Faits non Litigieux " ២៣ មីនា ២០១១, ERN 00655808-5809។

[5] មាត្រា៣១នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា១៣.១ នៃកិច្ចព្រមព្រៀង។ មាត្រា៣៥នៃច្បាប់អ.វ.ត.ក។ វិធាន២១.១.ឃ នៃវិធានផ្ទៃក្នុង។

[6] វិធាន៨៧.១ នៃវិធានផ្ទៃក្នុង។

មួយ ដែលត្រូវបានលើកឡើងចោទប្រកាន់ជាក់លាក់នៅក្នុងដីកាដំណោះស្រាយបាន នោះទេ។[7]

៥) សហព្រះរាជអាជ្ញា បញ្ជាក់អះអាងថា ខ្លួននឹងបន្តធ្វើសហប្រតិបត្តិការ និងស្វែងរកនូវកិច្ចសហប្រតិបត្តិការពីក្រុមមេធាវីការពារក្តីនានាជាទៀងទាត់ ដើម្បីឲ្យបានសម្រេចនូវការឯកភាពគ្នាមួយនៅលើអង្គហេតុ ឬពីបញ្ហាភស្តុតាងណាមួយក៏ដោយ ដែលអាចធ្វើទៅបាន។ បើសិនជាបាន ឈានទៅដល់ការឯកភាពគ្នាហើយនោះ ខ្លួននឹងជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងជាបន្ទាន់ភ្លាម[8]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |

[7] ឯកសារលេខ E9/19 "សារណាបឋមទាក់ទងនឹងអង្គហេតុដែលមិនជំទាស់តវ៉ា" ចុះថ្ងៃ ២៥ មីនា ២០១១ ERN00656168-6170។ ក្រុមមេធាវីការពារ នួន ជា បានអះអាងបន្ថែមក្នុងចំណោមនោះថា "នៅពេលបច្ចុប្បន្ននេះ កំពុងទទួលបានការណែនាំបន្ថែមពីនួន ជា ទាក់ទងនឹងអង្គហេតុមួយចំនួនដែលគាត់អាចនឹងមិនជំទាស់នៅក្នុងសវនាការ"នៅក្នុងថាខណ្ឌទី ៥។

[8] ដីកាបង្គាប់ដើម្បីរៀបចំសវនាការ, កថាខណ្ឌទី ១។